គជអប
NCDD

# គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

**ព្រឹត្តិបត្រព័ត៌មាន** ឆ្នាំទី១ លេខ២ ខែមេសា ឆ្នាំ២០១៥

គ.ជ.អ.ប មានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្នុងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ (ច្បាប់រៀបចំអង្គការ) ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។ ដើម្បីអោយការអនុវត្តច្បាប់ទាំងនេះមានប្រសិទ្ធភាព អ.ជ.អ.ប បានបង្កើតអនុគណៈកម្មាធិការមួយចំនួនដូចជា អនុគណៈកម្មាធិការមុខងារនិងធនធាន សារពើពន្ធនិងហិរញ្ញវត្ថុ បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងអនុគណៈកម្មាធិការផែនការអភិវឌ្ឍថ្នាក់ក្រោមជាតិ និងលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីសម្របសម្រួល និងគ្រប់គ្រងដំណើរការអនុវត្តនេះ៕

## អគាររដ្ឋបាល និងសាលប្រជុំសាលាក្រុង ស្រុក ចំនួន៣៤ ត្រូវបានធ្វើពិធីចុះបឋមសាលា

ការសាងសង់ ជួសជុល និងបំពាក់សម្ភារៈមួយចំនួនដល់អគាររដ្ឋបាល និងសាលប្រជុំសាលាក្រុង ស្រុក គឺជាសមាសភាគមួយសំខាន់ក្នុងចំណោមសមាសភាគផ្សេងទៀតដែលជួយអោយគម្រោងសេវាកម្មសាធារណៈ និងការគ្រប់គ្រងវិស័យហិរញ្ញវត្ថុតាមបែបវិមជ្ឈការសម្រេចបានតាមគោលដៅគ្រោងទុក ដោយសមាសភាគនេះមានតួនាទីក្នុងការរៀបចំកសាងមូលដ្ឋានគ្រឹះនៃលក្ខខ័ណ្ឌបំពេញការងាររបស់រដ្ឋបាលក្រុង ស្រក តាមរយៈការសាងសង់អគាររដ្ឋបាលក្រុង ស្រុក និងការបំពាក់នូវសម្ភារការិយាល័យចាំបាច់មួយចំនួនសម្រាប់ដំណើរការអនុវត្តការងាររបស់រដ្ឋបាលក្រុង ស្រុក ដែលត្រូវប្រើប្រាស់ថវិកាសរុបចំនួនប្រមាណ ១២ លានដុល្លារអាមេរិក នឹងត្រូវចំណាយរយៈពេល៩ខែ។

ពិធីបញ្ចុះបឋមសាលាតំណាងអោយអគាររដ្ឋបាល និងសាលប្រជុំទាំង៣៤ ត្រូវបានធ្វើឡើងក្រោមអធិបតីភាព ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) កាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ ២០១៥ នៅសាលាស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។

លក្ខណៈវិនិច្ឆ័យ និងល័ក្ខខ័ណ្ឌមួយចំនួនក្នុងការជ្រើសរើសសាលាក្រុង ស្រុកមាន៖ ទី ១) ស្ថានភាពអគារសាលាក្រុង ស្រុកដែលមានស្ថានភាពលំបាកក្នុងការបំពេញការងារ (មានមេគុណ៧០%) ២) ចំនួនប្រជាពលរដ្ឋរបស់ក្រុង ស្រុក (មានមេគុណ១៥%) និងទី៣) កត្តាភាពក្រីក្ររបស់ក្រុង ស្រុក (មានមេគុណ១៥%)។ ការជ្រើសរើសនេះបានធ្វើឡើងតាមលក្ខណៈវិនិច្ឆ័យ និងរូបមន្តដោយធានាបាននូវតម្លាភាពពិតប្រាកដ ដោយអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃបានបង្កើតបញ្ជីឈ្មោះក្រុង ស្រុក អាទិភាពតាមលំដាប់លំដោយ ដោយក្នុងនោះមានអាគារក្រុង ស្រុក និងសាលប្រជុំចំនួន៣៤ ក្នុងចំណោមខេត្តចំនួន១៨ ត្រូវបានជ្រើសរើសក្នុងការអនុវត្តគម្រោងនេះជំហានទី១។ ខេត្តដែលត្រូវអនុវត្តគម្រោងមាន ខេត្តបន្ទាយមានជ័យមានចំនួន០២ ស្រុក បាត់ដំបងមានចំនួន០៤ ស្រុក កំពង់ចាមមានចំនួន០១ ស្រុក កំពង់ឆ្នាំងមានចំនួន០៣ ស្រុក កំពង់ធំមានចំនួន០១ ស្រុក កំពតមានចំនួន០១ ស្រុក កោះកុងមានចំនួន០២ ស្រុក ក្រចេះមានចំនួន០១ ស្រុក មណ្ឌលគិរីមានចំនួន០៣ ស្រុក ព្រះវិហារមានចំនួន០៣ ក្រុង ស្រុក ព្រៃវែងមានចំនួន០២ ក្រុង ស្រុកពោធិ៍សាត់មានចំនួន០១ ស្រុក រតនគិរីមានចំនួន០២ ស្រុក សៀមរាបមានចំនួន០១ ស្រុក ស្ទឹងត្រែងមានចំនួន០២ ស្រុក តាកែវមានចំនួន០៣ ស្រុក ឧត្តរមានជ័យមានចំនួន០១ ស្រុក និងខេត្តប៉ៃលិនមានចំនួន០១ ស្រុក។

ដើម្បីជួយគាំទ្រដល់រាជរដ្ឋាភិបាលក្នុងការសម្រេចនូវកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នៅឆ្នាំ២០១៣ បានផ្តល់ប្រាក់កម្ចីចំនួន១៣,៥ លានដុល្លារអាមេរិក ដល់រាជរដ្ឋាភិបាលក្នុងការអនុវត្តគម្រោងសេវាកម្មសាធារណៈ និងការគ្រប់គ្រងវិស័យហិរញ្ញវត្ថុតាមបែបវិមជ្ឈការ ក្នុងនោះមានថវិកាបដិភាគរបស់រាជរដ្ឋាភិបាលចំនួន១ លានដុល្លារអាមេរិក។



រូបភាពគំរូសាលាក្រុង ស្រុក និងសាលប្រជុំដែលគាំទ្រថវិកាដោយ ADB


ឯកឧត្តម ស ខេង ក្នុងពិធីបញ្ចុះបឋមសាលាសាងសង់សាលាក្រុង ស្រុក

# ក្រសួងអាទិភាពចំនួន៨ ត្រូវបានតម្រង់ទិសពីដំណើរការផ្ទេរមុខងារ និងធនធាន អោយដល់រដ្ឋបាលថ្នាក់ក្រោមជាតិ

បន្ទាប់ពីក្រសួងចំនួន៦ បានរៀបចំពិនិត្យមើលមុខងារ និងធនធាន ព្រមទាំងបានសាកល្បងផ្ទេរមុខងារ និងធនធានដល់ក្រុង ស្រុកមួយចំនួនរួចមក លេខាធិការដ្ឋានគ.ជ.អ.ប បានប្រជុំតម្រង់ទិសដល់ក្រសួងអាទិភាពចំនួន៨ផ្សេងទៀតពីនីតិវិធី និងកិច្ចដំណើរការក្នុងការរៀបចំផ្ទេរមុខងារ និងធនធានដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

កិច្ចការតម្រង់ទិសនេះគឺ បានពន្យល់លម្អិតពីខ្លឹមសារអនុក្រឹត្យលេខ៦៨ និងសេចក្តីណែនាំបច្ចេកទេសពាក់ព័ន្ធនឹងកិច្ចដំណើរការផ្ទេរមុខងារ និងធនធានដើម្បីអោយក្រសួងទាំង៨ រៀបចំជាជំហានក្នុងការរៀបចំបញ្ជីវិភាគមុខងារដើម្បីកំណត់ពីកិច្ចការមួយចំនួនដែលត្រូវផ្ទេររួមមាន៖

- មុខងារដែលក្រសួងកំពុងអនុវត្តជាក់ស្តែង
- អង្គភាពដែលគ្រប់គ្រង និងទទួលខុសត្រូវលើការអនុវត្តការងារទាំងនោះ
- ក្របខ័ណ្ឌច្បាប់ជាមូលដ្ឋានសម្រាប់ការបំពេញការងារទាំងនោះ
- ធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស មធ្យោបាយ សម្ភារៈ បរិក្ខារ និងធនធានផ្សេងទៀតជាក់ស្តែងនាពេលបច្ចុប្បន្ន ដែលចាំបាច់ដើម្បីអនុវត្តមុខងារទាំងនោះ។

ដើម្បីអោយក្រសួងថ្មីទាំង៨កាន់តែមានភាពងាយស្រួលយល់ពីដំណើរការរៀបចំផ្ទេរមុខងារ និងធនធាន តំណាងក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងបរិស្ថាន ក៏បានចែករំលែកបទពិសោធន៍កន្លងមកដែលក្រសួងទាំង២ បានកំពុងសាកល្បងផ្ទេរមុខងារ និងធនធានមួយចំនួនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលក្នុងនោះក្រសួងបរិស្ថានបានផ្ទេរមុខងារគ្រប់គ្រងសំណល់រឹង រាវ និងលូទឹកស្អុយ និងការប្រមូលសំរាម ដោយឡែកក្រសួងអប់រំ យុវជន និងកីឡាគ្រោងអនុវត្តសាកល្បងមត្តេយ្យសិក្សាសហគមន៍ និងសិស្សសហគមន៍។

ក្រសួងក្នុងវិស័យអាទិភាពចំនួន៨មានដូចជា៖ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងពាណិជ្ជកម្ម ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងរ៉ែ និងថាមពល ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងទេសចរណ៍ និងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់។

វិស័យ ឬកិច្ចការអាទិភាព និងក្រសួងដែលពាក់ព័ន្ធក្នុងការផ្ទេរមុខងារ៖

| វិស័យ ឬកិច្ចការអាទិភាព | ក្រសួងដែលពាក់ព័ន្ធ |
|---|---|
| វិស័យអប់រំ | ក្រសួងអប់រំ យុវជន និងកីឡា |
| កសិកម្ម | ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ |
| ជលផល | ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ |
| ព្រៃឈើ ធនធានធម្មជាតិ | ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ |
| | ក្រសួងបរិស្ថាន |
| ការគ្រប់គ្រងទឹក | ក្រសួងធនធានទឹក និងឧតុនិយម |
| ការអភិវឌ្ឍន៍ជនបទ | ក្រសួងអភិវឌ្ឍន៍ជនបទ |
| សង្គមកិច្ច | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| សុខាភិបាល អាហារូបត្ថម្ភ និងសេវាប្រជាជនរួមទាំងតម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ កុមារ ជនងាយរងគ្រោះ និងជន ជាតិដើមភាគតិច | ក្រសួងសុខាភិបាល |
| | ក្រសួងអភិវឌ្ឍន៍ជនបទ |
| | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ក្រសួងកិច្ចការនារី |
| ការប្រើប្រាស់ដីធ្លី | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ការងារសុរិយោដី សំណង់ | |
| ការផលិត ចែកចាយអគ្គីសនី | ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល |
| ឧស្សាហកម្ម និងការគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ច | ក្រសួងឧស្សាហកម្ម រ៉ែ ថាមពល |
| | ក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ, ពាណិជ្ជកម្ម |
| តម្រូវការពិសេស ឬតម្រូវការដែលបានកំណត់ជាកំលាក វិស័យទេសចរណ៍ តំបន់ប្រវត្តិសាស្ត្រ និងកេរតំណែលវប្បធម៌ | ក្រសួងទេសចរណ៍ |
| | ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ |

